# ការសម្ភាសរបស់បងប្រុស វ៉េត វណ្ណៈ

**កៈ អ្នកសម្ភាស ញ៉េម សុគន្ធា** **ខៈ អ្នកត្រូវគេសម្ភាស វ៉េត វណ្ណៈ**

កៈ អញ្ចឹងជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់បងប្រុសដែលឱ្យខ្ញុំសម្ភាសអំពីជីវប្រវត្តិរបស់បង នាងខ្ញុំឈ្មោះ ញ៉េម សុគន្ធា ជាអ្នកសម្ភាស។បងតើឈ្មោះពេញរបស់បង បងឈ្មោះអីគេដែរ?

ខៈ ឈ្មោះ វ៉េត វណ្ណៈ។

កៈ ចាសថ្ងៃនេះខ្ញុំសម្ភាសបងប្រុសនៅក្នុងថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៦។ ការសម្ភាសនេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យនៅប្រទេសអាមេរិច ឈ្មោះថា ប៊ី វ៉ាយ យូ សកលវិទ្យាល័យមានកម្មវិធីដើម្បីសម្ភាសអំពីជីវប្រវត្តិរបស់បងក៏ដូចជាប្រជាពលរដ្ឋខ្មែរដើម្បីនាពេលអនាគតទៅកូនចៅរបស់បងនិងមនុស្សជំនាន់ក្រោយអាចដឹងអំពីជីវប្រវត្តិនិងដំណើររឿងក៏ដូចជាឆាកជីវិតរបស់បងផងដែរ។ អញ្ចឹងបងប្រុស តើអនុញ្ញាតឱ្យខ្ញុំដាក់ការសម្ភាសនេះចូលទៅក្នុងវេបសាយរបស់សកលវិទ្យាល័យ ប៊ី វ៉ាយ យូ ដែរឬទេ?

ខៈ បាទបាន។

កៈ ចាសអញ្ចឹងដែលវេបសាយនេះមានឈ្មោះថា www.cambodianoralhistoryproject.byu.edu ហើយ នាងខ្ញុំសូមចាប់ផ្ដើមសម្ភាសដល់បងប្រុស អញ្ចឹងបងតើបងសូមប្រាប់ឈ្មោះពេញរបស់បងម្ដងទៀត?

ខៈ ខ្ញុំឈ្មោះ វ៉េត វណ្ណៈ។

កៈ បងមានឈ្មោះហៅក្រៅអត់?

ខៈ ឈ្មោះណាក់ទទេ។

កៈ តែណាក់ទទេ អញ្ចឹងបងចាំទេតើបងកើតនៅក្នុងថ្ងៃខែឆ្នាំណាដែរ?

ខៈ ខ្ញុំកើតនៅ៨៥(១៩៨៥)។

កៈ ឆ្នាំ១៩០០ប៉ុន្មានបង?១៩៨៥?

ខៈ បាទ១៩៨៥។

កៈ បងចាំថាកើតនៅខែណាទេ?

ខៈ ខ្ញុំភ្លេចដែរហើយ។

កៈ ភ្លេចបាត់ហើយ?

ខៈ បាទ!

កៈ ចាសអញ្ចឹងបងតើទីកន្លែងកំណើតរបស់បងប្រុសនៅឯណាវិញ?

ខៈ ខ្ញុំនៅកើតនៅព្រែកលៀប។

កៈ នៅព្រែកលៀប?

ខៈ នៅភ្នំពេញ។

កៈ នៅឃុំអីដែរបង?

ខៈ ដឹងឃុំអី។

កៈ ស្រុកអីគេបងនៅហ្នឹង?

ខៈ អឺ...គេហៅតែភូមព្រែកលៀប ភូមិព្រែកលៀប។

កៈ ចាសនៅខេត្តកណ្តាលហោ?

ខៈ នៅខេត្តកណ្តាល ហ្នឹងហើយខេត្តកណ្តាល។

កៈ ចាសអញ្ចឹងបងចាំទេថាបងឆ្នាំខ្មែរបងកើតសត្វអីគេដែរ?

ខៈ ខ្ញុំខាល។

កៈ ឆ្នាំខាល អញ្ចឹងបងតើបងមានបងប្អូនប្រុសស្រីប៉ុន្មាននាក់ដែរ?

ខ៖ ខ្ញុំមានៗស្រី២នាក់ហើយនឹងប្រុស២នាក់។

ក៖ ចាសអញ្ចឹងបងជាកូនទីប៉ុន្មានវិញ?

ខ៖ ទី...ខ្ញុំកូនច្បង។

ក៖ កូនច្បងគេ?

ខ៖ បាទ!

ក៖ ចាសអញ្ចឹងបង តើបងប្អូនបងគាត់នៅរស់ទាំងអស់ឬក៏ពួកគាត់យ៉ាងម៉េចដែរ?

ខ៖ បាទពួកគាត់នៅទាំងអស់។

ក៖ ហើយពួកគាត់នៅឯណាវិញ?

ខ៖ គាត់នៅកំពង់សោម ខ្ញុំនៅកំពង់ចាម។

ក៖ ចាស!

ខ៖ ឆ្ងាយពីគ្នា។

ក៖ ចាសឆ្ងាយខ្លាំងណាស់។

ខ៖ បាទ!

ក៖ ចាសអញ្ចឹងបង តើឪពុករបស់បងគាត់ឈ្មោះអីគេដែរ?

ខ៖ ឪពុកខ្ញុំមានឪពុកចុងក្រោយគាត់ឈ្មោះភណ្ឌ័ ហើយឪពុកបង្កើតរបស់ខ្ញុំឈ្មោះធី។

ក៖ ធី អីគេធី?

ខ៖ ឈ្មោះអឺ...គាត់ឈ្មោះខ្ញុំភ្លេចជីតាខ្ញុំបាត់ហើយ ព្រោះខ្ញុំបែកពីគាត់តាំងពីនៅតូចម្លេះ។

ក៖ ចាសអត់ស្គាល់ឈ្មោះត្រកូលគាត់ទេហី?

ខ៖ បាទ!

កៈ ចាសអញ្ចឹងបងចាំទេថាប៉ាបងគាត់កើតនៅឆ្នាំណា?

ខៈ ខ្ញុំអត់សូវចាំដែរព្រោះបែកពីគាត់។

កៈ ចាំជំនាន់ទេ?

ខៈ គាត់ខ្ទង់ប្រហែលជា៣៥ហើយឥឡូវ។

កៈ អ្នកណាគេ៣៥?

ខៈ ប៉ាបង្កើតរបស់ខ្ញុំ។

កៈ ហើយបងឯង៣១ ហើយម៉េចគាត់៣៥?

ខៈ ព្រោះប៉ាចុង។

កៈ ប៉ាចុងហេ?

ខៈ បាទ!

កៈ រកប៉ាបង្កើត?

ខៈ ប៉ាបង្កើតគាត់ក៏នៅក្មេងដែរ គាត់ប្រហែលជា៥០។

កៈ ៥៥ ៥៦អញ្ចឹងទៅ?

ខៈ បាទៗប្រហែលជា៥០។

កៈ ចាសអញ្ចឹងដកគុណចែកអីតាមហ្នឹងទៅឃើញអាយុគាត់ហើយ។អញ្ចឹងបងចាំទេថាទីកន្លែងកំណើតរបស់ប៉ាបងបង្កើត មិនមែនប៉ាចុងទេ ប៉ាបង្កើតហានៅឯណាវិញ?

ខៈ ប៉ាបង្កើតគាត់នៅភ្នំពេញ។

កៈ នៅភ្នំពេញ?

ខៈ បាទគាត់នៅបុរីកីឡា។

កៈ ចាសនៅបុរីកីឡាហ្នឹងហើយ។

ខៈ បាទគាត់មានផ្ទះនៅហ្នឹង។

កៈ ចាសហ្នឹងហើយ។

ខៈ ធ្លាប់ទៅលេងគាត់ម្ដងដែរ។

កៈ ចុះពេលស្រុកកំណើតគាត់ហ្មងនៅឯណាវិញ?

ខៈ នៅព្រៃវែង។

កៈ ព្រៃវែង?

ខៈ បាទ!

កៈ អញ្ចឹងបងតើបងចងចាំអីគេខ្លះជាមួយនឹងឪពុកបងហា គាត់ឪពុកបង្កើត តើគាត់បានផ្ដល់សេចក្ដីស្រលាញ់ក៏ដូចជាមើលថែរក្សាគ្រួសារម៉េចដែរ គាត់មានចរិកលក្ខណៈម៉េចដែរអញ្ចឹងហា?

ខៈ គាត់ស្រលាញ់ខ្ញុំ។

កៈ ចាស!

ខៈ គាត់...បាទគាត់ធ្លាប់ទៅយកខ្ញុំនៅឯព្រែកលៀប គាត់យកខ្ញុំនៅជាមួយគាត់នៅផ្សារអីគេគេហៅម្លប់តាប៉ាងអីនោះ។

កៈ ចាសប្លុកគេធ្វើផ្ទះតូចៗហ្នុំ...។

ខៈ អញ្ចឹងគាត់ធ្លាប់យកខ្ញុំទៅនៅ ឱ្យខ្ញុំរៀនតាំងពីភាសាខ្មែរ អង់គ្លេស។

កៈ ចាស!

ខៈ ហើយខ្ញុំមានប្អូនស្រីម្នាក់ឈ្មោះ ឈ្មោះអឺ...វណ្ណ នីដា។

កៈ ចាស!

ខ៖ ដែលគេជាតារាចម្រៀងបាទ។

ក៖ ហ្ហ៎...ហ្នឹងហើយ ចាសអញ្ចឹងបងសម្រាប់ម្ដាយរបស់បងវិញ តើម្ដាយរបស់បងគាត់ឈ្មោះអី?

ខ៖ ម្ដាយខ្ញុំគាត់ឈ្មោះ សេន។

ក៖ សេន អីគេសេន?

ខ៖ បាទ យន់ សេន។

ក៖ យន់ សេន បងចាំទេថាគាត់កើតនៅឆ្នាំណា?

ខ៖ ខ្ញុំអត់បានចាំដែរពីព្រោះមិនបានសួរគាត់។

ក៖ ចាសចុះឥឡូវគាត់អាយុប៉ុន្មានហើយ?

ខ៖ ឥឡូវគាត់អាយុចូល៩០ហើយ។

ក៖ ៩០ប៉ុន្មានហើយ?

ខ៖ ៩២ ៩៣ហើយ។

ក៖ ម្ដាយបង្កើតហ្ហ៎...?

ខ៖ បាទ!

ក៖ អត់កើតទេដោយសារបងឯង៣១ហើយហ្នឹង គាត់អាយុ៩២ ៩៣ ម៉េចកើត?

ខ៖ ហ្នឹងហើយខ្ទង់៥០ហើយព្រោះខ្ញុំមិនសួរចាំពីគាត់។

ក៖ អត់សួរចាំ អត់សួរចាំពីគាត់ទេ។

ខ៖ មើលទៅគាត់រៀងក្មេងដែរ។

ក៖ តែតាមពិតគាត់៥០ជាងហើយហោ?

ខ៖ អត់ដែលសួរគាត់ផង។

ក៖ ចាសហ្នឹងហើយ។

ខ៖ ឆ្នាំកោ ៥០ជាងហើយ ឆ្នាំកោបាទ។

ក៖ ចុះប៉ាបងគាត់ឆ្នាំអីគេដែរអញ្ចឹង?

ខ៖ ប៉ាបង្កើតហ្នឹងគាត់ឆ្នាំខាលដែរ។

ក៖ ឆ្នាំខាលដែរចាស។

ខ៖ បាទ!

ក៖ អញ្ចឹងបងតើទីកន្លែងកំណើតម៉ាក់បងនៅឯណាវិញ?

ខ៖ នៅកំពង់សោម។

ក៖  កំពង់សោម គាត់កើតនៅកំពង់សោមហ្នឹងហ្មងហេ?

ខ៖ អត់ទេគាត់នៅនេះតើ ស្រុកកំណើតនៅព្រៃកលៀបនេះដែរហ្នឹង។

ក៖ ព្រៃកលៀបដែរ?

ខ៖ ខេត្តកណ្តាលហ្នឹង។

ក៖ ហេតុអីគាត់ទៅនៅកំពង់សោម?

ខ៖ គាត់បែកបាក់គ្នាទៅ គាត់ទៅខាងកំពង់សោមហ្នឹង។

ក៖ ចាសរកស៊ីបកក្តាម បកបង្គាពីមុនហា។

ក៖ ចាស!

ខ៖ តែឥឡូវគាត់រាងធូរគួរសមរបស់គាត់។

ក៖ ចាស!

ខ៖ គាត់អត់មានធ្វើការអីទៀតទេ គាត់ចាំតែកម្លាំងប្តីគាត់ក្រោយ ប្តីចុងហ្នឹងហា។

ក៖ ចាសរកស៊ីចិញ្ចឹមទៅ?

ខ៖ បាទ!

ក៖ អញ្ចឹងបង បងអាចរៀបរាប់ពីជីវិតបងដែលពេលរស់នៅជា មួយម្តាយបង តើវាយ៉ាងម៉េចដែរបង?

ខ៖ ម្តាយបង្កើតរបស់ខ្ញុំហ្ន៎...?

ក៖ ចាសពេលបងរស់នៅជាមួយគាត់ហា មានការចងចាំអីគេខ្លះ?

ខ៖ ខ្ញុំនៅជាមួយគាត់ កាលខ្ញុំនៅតូចពិបាកដែរ។

ក៖ ម៉េចវិញ?

ខ៖ វាជីវភាពខ្សត់ខ្សោយ ហូបចុកមិនសូវបានគ្រប់គ្រាន់ រៀនអីក៏មិនបានគ្រប់គ្រាន់នឹងគេ ដែរ។

ក៖ ចាស!

ខ៖ អញ្ចឹងប្តីប្រពន្ធគាត់មានការឈ្លោះគ្នាប្រកែកគ្នាទៅខ្ញុំអត់បានទៅរៀន។

ក៖ អញ្ចឹងទៀត?

ខ៖ បាទជួយធ្វើការគាត់រកលុយដើម្បីដោះស្រាយជីវភាពគាត់។

ក៖ ចិញ្ចឹមប្អូន ចិញ្ចឹមអីអញ្ចឹងទៅ?

ខ៖ បាទចិញ្ចឹមប្អូន មើលប្អូន។

ក៖ អញ្ចឹងបងសម្រាប់ជីតាខាងឪពុកបង ជីដូនជីតាឈ្មោះអីគេដែរតាអីយាយអី?

ខ៖ អឺ...ខ្ញុំចាំបានតែយាយខ្ញុំ យាយខ្ញុំឈ្មោះ យាយផាន់។

ក៖ ខាងឪពុកហ្នឹងហេ?

ខ៖ បាទ!

ក៖ ចាសឥឡូវគាត់រស់ឬក៏ស្លាប់វិញ?

ខ៖ អឺ...គាត់នៅរស់ទេ យាយផាន់ហ្វូ...បើតាគាត់ស្លាប់ហើយ តែទៅថ្ងៃមុនខ្ញុំភ្លេចអត់បានសួរឈ្មោះជីតាព្រោះខ្ញុំបែកតាំងពីតូច៦ខែក្នុងពោះម៉ាក់ខ្ញុំម្ល៉េះ។

ក៖ ហ្ហ៎...!

ខ៖ បែកគ្នា។

ក៖ ចាសអញ្ចឹងតើយាយអាយុប៉ុន្មានហើយ?

ខ៖ យាយគាត់...ខ្ញុំអត់សួរដឹងដែរនេះ តែគាត់ខ្ទង់ប្រហែលជា៧០ជាងហើយមើលទៅ។

ក៖ អញ្ចឹងបងចាំទេថាកន្លែងកំណើតរបស់យាយបងគាត់នៅឯណាវិញ?

ខ៖ ឥឡូវហ្នឹងគាត់នៅអឺ...នៅភ្នំពេញគេហៅថា...។

ក៖ តែកន្លែងគាត់កើតហាបង?

ខ៖ កន្លែងគាត់កើត...។

ក៖ ស្រុកកំណើតគាត់ហា?

ខ៖ នៅព្រៃវែង។

ក៖ នៅព្រៃវែងហ្មង?

ខ៖ បាទ!

ក៖ ចាសហ្នឹងហើយ អញ្ចឹងចាំទេថាយាយគាត់កើតឆ្នាំសត្វខ្មែរ គាត់កើតឆ្នាំសត្វអីគេបង?

ខ៖ ខ្ញុំអត់បានសួរគាត់ផង ព្រោះបានជួបគាត់តែមួយភ្លេតៗ។

ក៖ អញ្ចឹងពេលបងបានជួបគាត់មានអនុស្សាវរីយ៍អីខ្លះជាមួយគាត់តាំងពីក្មេងមកបង?

ខ៖ ខ្ញុំជួបគាត់មានអនុស្សាវរីយ៍ កាលហ្នឹងខ្ញុំទៅនៅជាមួយគាត់ កាលហ្នឹងប៉ាខ្ញុំគាត់យកទៅនៅគាត់បាន...គាត់ដូចជាឱ្យពីយើងហូបបាយដូចថាជាការបញ្ចុកខ្ញុំនៅពីតូចអីអញ្ចឹងទៅណាបងដែរ ដូចថាគាត់រវល់ការងារគាត់ទិញពងមាន់ ពងអីទៅលក់អញ្ចឹងទៅ។

ក៖ ចាស!

ខ៖ នៅសល់អីផាតហ្នឹងគាត់ឃើញជើងខ្ញុំដំបៅអញ្ចឹង គាត់យកខ្ញុំទៅផ្ទះគាត់លេង ដំបូងគាត់ដុសយកច្រាសយកអីដុសឱ្យ គាត់ស្រលាញ់ក្មួយអាណិតយល់គាត់កន្លែងហ្នឹងដែរ។

ក៖ ហ្នឹងហើយ អញ្ចឹងតាបងអត់ចាំអីសោះហ្មងហេ?

ខ៖ បាទ!

ក៖ មិញខាងឪពុកមែនទេបង?

ខ៖ បាទ!

ក៖ ចុះសម្រាប់ខាងម្ដាយវិញម្ដង អញ្ចឹងបងស្គាល់ឈ្មោះតាយាយទេ?

ខ៖ បាទខ្ញុំស្គាល់។

ក៖ យាយអី តាអីដែរបង?

ខ៖  ឈ្មោះតារ៉េត គាត់ស្លាប់បាត់ហើយ ។

ក៖ ចាស!

ខ៖ នៅតែយាយឈៀប។

ក៖ ចាស!

ខ៖ ខាងនេះទេ ខាងឪពុកចុង។

ក៖ ខាងឪពុកដើមហា?

ខ៖ ខាងឪពុកដើមដូចខ្ញុំនិយាយម៉េចអញ្ចឹងឈ្មោះយាយផាន់។

ក៖ យាយផាន់ តាអីដែរបង?

ខ៖ តាស្លាប់បាត់ហើយភ្លេចឈ្មោះគាត់ហើយ។

ក៖ ចាស!

ខ៖ ស្លាប់យូរហើយ។

ក៖ ចាសខាងម្តាយរបស់បងហេ?

ខ៖ អាហ្នឹងខាងឪពុកទេ។

ក៖ អញ្ចឹងខាងម្តាយរបស់បងវិញ?

ខ៖ ខាងម្តាយឈ្មោះតាឈុំ។

ក៖ យាយអីវិញបង?

ខ៖ យាយឈ្មោះយាយសន។

ក៖ យាយសន?

ខ៖ បាទ!

ក៖ បងចាំថាពួកគាត់កើតនៅពេលណាទេ?

ខ៖ ខ្ញុំអត់សូវចាំដែរ ព្រោះខ្ញុំក្មេងសារក្រោយ។

ក៖ ចាសហ្នឹងហើយ។

ខ៖ ខ្ញុំមិនដែលបានសួរម្តាយ។

ក៖ ហ្នឹងហើយមិនដែលសួរ អញ្ចឹងបងចាំថាទីកន្លែងកំណើតតាយាយ គាត់នៅឯណាស្រុកកំណើតគាត់ហា?

ខ៖ ស្រុកកំណើតគាត់ គាត់នៅខេត្តកណ្តាលហ្នឹងដែរ ពីដើមគាត់មេកន្ទុយលេខ។

កៈ កន្ទុយលេខមានតាំងពីយូរបងហេ?

ខៈ បាទ!

កៈ ហ្នឹងហើយ!

ខៈ ពីដើមមកគាត់មានតែគាត់។

កៈ ចុះតាបងគាត់ឆ្នាំអីគេបងចាំទេ?

ខៈ តាខ្ញុំអត់ស្គាល់ អត់ចាំផងព្រោះខ្ញុំអត់បានស្គាល់។

កៈ ចុះយាយយាយឆ្នាំអីគេដែរ?

ខៈ គាត់ស្លាប់តាំង តាំងពីខ្ញុំនៅតូច។

កៈ ចាស!

ខៈ បាទអត់ស្គាល់។

កៈ ចាសអត់ស្គាល់ទាំង២?

ខៈ បាទ!

កៈ ចាសអញ្ចឹងបង តើបងមានការចងចាំអីគេខ្លះជាមួយជីដូនជីតាខាងម្តាយហ្នឹង?

ខៈ ចងចាំថានៅតូចៗអីអញ្ចឹងគាត់ហូបបាយ ហូបអីអញ្ចឹងគាត់ច្រើនតែហៅខ្ញុំទៅ។

កៈ ចាស!

ខៈ គាត់ស្រលាញ់ខ្ញុំ គាត់ហូបមិនដែលអស់ទេ គាត់ហៅទៅហូប ទុករបស់ឱ្យខ្ញុំហូបរហូត។

កៈ ចាស!

ខៈ មួយថៅមានតែគាត់ស្រលាញ់ខ្ញុំជាងគេ។

កៈ ពិសេសជាងគេអញ្ចឹងហេ?

ខ៖ បាទតែត្រូវមាត់ជាងគេ។

ក៖ ស្រលាញ់ជាងគេត្រូវតែត្រូវមាត់ជាងគេហើយ។

ខ៖ បាទ!

ក៖ អញ្ចឹងបងតើឪពុកម្តាយឬក៏ជីដូនជីតារបស់បងហា ពួកគាត់មានធ្លាប់ទៅរស់នៅប្រទេសក្រៅអីទេ?

ខ៖ អត់ផង គាត់រស់នៅប្រទេសខ្មែររហូត។

ក៖ ចាសអញ្ចឹងបងដល់ការសិក្សាវិញម្តង តើបងរៀនដល់ថ្នាក់ទីប៉ុន្មានដែរ?

ខ៖ ខ្ញុំរៀនបានតិចហាកាលហ្នឹង រៀនបានថ្នាក់ទី១ពេលខ្ញុំជិតបានឡើងបានថ្នាក់ទី២ ម្តាយខ្ញុំគាត់រើទៅនៅកន្លែងទីផ្សេងទៅ។

ក៖ ចាស!

ខ៖ កាលមុនគាត់នៅភូមិទួលព្រៃក ខេត្តកំពង់ចាម ពេលថាដូចថាគាត់ចង់ដូរទីលំនៅអញ្ចឹងខ្ញុំទៅផ្សេងទៀត ទៅរកប៉ា។

ក៖ ចាស!

ខ៖ ទៅដល់កំពង់សោមកាលពេលហ្នឹង ហ្ន៎...ទៅកោះកុង។

ក៖ បានឆ្ងាយទៀត?

ខ៖ ទៅកោះកុងទៅរកស៊ីហ្នឹងខ្ញុំអត់បានរៀនបណ្តោយ ខ្ញុំចុះទូកដើម្បីរកលុយជួយជីវភាព គាត់។

ក៖ ហ្នឹងហើយ!

ខ៖ កម្សត់ណាស់។

ក៖ ចុះបងបងរៀននៅថ្នាក់ទី១ហ្នឹង បងរៀននៅសាលាណាវិញ?

ខ៖ នៅសាលាភូមិទួលព្រៃក។

ក៖ ចាស!

ខ៖ ខេត្តកំពង់ចាម។

ក៖ បងមានបានរៀនភាសាអីផ្សេងពីភាសាខ្មែរទេ?

ខ៖ ខ្ញុំរៀនដែរប៉ុន្តែអត់សូវចាំ អត់សូវចេះ។

ក៖ ចាស!

ខ៖ រៀនបានតិច។

ក៖ ចាសអញ្ចឹងបងធ្លាប់ធ្វើរបរស្រែចម្ការអីអត់?

ខ៖ ខ្ញុំកាលមុនធ្លាប់ដែរ។

ក៖ មានដាំចម្ការបន្លែផ្លែឈើអីទេ?

ខ៖ បើកាលហ្នឹងខ្ញុំទៅដល់ឮថាបងថ្លៃ ហើយខ្ញុំខាងប្រពន្ធនៅខាងមេមត់គេធ្វើចម្ការបានខំទៅធ្វើចម្ការដាំដំឡូងមីបានកន្លះហត្ថដែរ។

ក៖ ហ្ហំ...ហើយមានបានទទួលផលច្រើនទេ?

ខ៖ ទទួលផលវាមិនសូវបានច្រើនដែរ បានដូចថាភាគច្រើនគេមកសុំម៉ៅអញ្ចឹងយើង៥០ ៦០សិបម៉ឺនហ្នឹងម៉ៅឱ្យគេទៅ យើងគ្រាន់តែដាំហើយគេម៉ៅ គេឃើញលាស់ល្អគេម៉ៅយក។

ក៖ ចាសអញ្ចឹងបងសម្រាប់មួយទៀតវិញ សម្រាប់ជីវិតអាពាហ៍ពិពាហ៍វិញ តើបងរៀបការនៅថ្ងៃខែឆ្នាំណាដែរបង?

ខ៖ ឆ្នាំ២០១១។

ក៖ ខែប៉ុន្មានបង?

ខ៖ ខែ០២។

កៈ អញ្ចឹងបងរៀបការរៀបការនៅឯណាវិញ?

ខៈ នៅភូមិទួលព្រៃក ខេត្តកំពង់ចាម ខាងព្រៃសរ។

កៈ ចាសអញ្ចឹងបង តើការរៀបការរបស់បងហ្នឹងហា រៀបចំឡើងដោយឪពុកម្ដាយបងឬក៏បងស្រលាញ់គ្នាជាមួយប្រពន្ធបងដោយខ្លួនឯង?

ខៈ ខ្ញុំរៀបចំឡើងដោយឪពុកម្ដាយនិងចូលស្ដីដណ្ដឹង។

កៈ ចាសអញ្ចឹងបងជួបគ្នាដំបូងជាមួយបងវេតនៅឯណាវិញ?

ខៈ ខ្ញុំជួបគ្នាដំបូងឪពុកម្ដាយខ្ញុំនៅភូមិទួលព្រៃកហ្នឹងគាត់ ខ្ញុំទៅរៀនជាមួយគ្នាហ្នឹងទៅនៅតូចលេងជាមួយគ្នាទៅក៏បានស្គាល់។

កៈ អញ្ចឹងស្គាល់គ្នាតាំងពីក្មេងហោ?

ខៈ បាទពេលខ្ញុំបែកទៅ ខ្ញុំទៅនៅកំពង់សោម ខ្ញុំក៏បានជួបគាត់ទៅ។

កៈ ហ្នឹងហើយ!

ខៈ មកវិញទៅក៏ស្រលាញ់គ្នា។

កៈ ក៏រៀបការទៅ។

ខៈ បាទ!

កៈ ចាសអញ្ចឹងបងការរៀបការ បងមានបណ្ណាការការឱ្យទៅខាងស្រីអីទេ?

ខៈ បាទឱ្យគាត់តើ។

កៈ ឱ្យចាសដោយសារតែទំនៀមទម្លាប់ខ្មែរគឺបែបហ្នឹង។

ខៈ បាទ!

កៈ ចាសអញ្ចឹងបងការប្រៀប ធៀបពីជីវិតរបស់បងពីអតីតកាលមកបច្ចុប្បន្នកាលហ្នឹង វាខុសគ្នាម៉េចដែរបង ពីមុនស្រួលជាងឬក៏ពីមុនពិបាកជាងឬក៏ម៉េចដែរ?

ខ៖ ពីមុនពិបាក តែឥឡូវវាគ្រាន់បើតិច។

ក៖ គ្រាន់បើតិច វាយ៉ាងម៉េចដែរបងអាចរៀបរាប់ឱ្យបានក្បោះក្បាយអញ្ចឹងហា?

ខ៖ ពេលឥឡូវដូចថាខ្ញុំមានចំណេះ ធ្លាប់រៀនពីនៅកម្លោះធ្វើជាជាងម៉ាស៊ីន ថាធ្លាប់ធ្វើការស៊ីឈ្នួលគេអញ្ចឹង ដកពិសោធន៍យើងយកមកដើម្បីយើងសល់លុយសល់កាក់យើងបើកកន្លែងខ្លួនឯង។

ក៖ ចាស!

ខ៖ ធ្វើជាងម៉ាស៊ីន ធ្វើជាងម៉ូតូ។

ក៖ ចាស!

ខ៖ ជាងម៉ាស៊ីនគ្រប់ប្រភេទ។

ក៖ ចាសអញ្ចឹងបងចេះទាំងអស់ហ្នឹងហេ?

ខ៖ បាទខ្ញុំចេះម៉ាស៊ីនសាំង ម៉ាស៊ីនម៉ាស៊ូត។

ក៖ ចាស!

ខ៖ ធ្វើម៉ូតូ។

ក៖ ចាសហ្នឹងហើយ។

ខ៖ ចេះច្រើន អញ្ចឹងបងតើម្ហូបអ្វីដែលបងចូលចិត្តពិសារជាងគេហា?

ខ៖ ខ្ញុំហ្ន៎...?

ក៖ ចាស!

ខ៖ កាលមុនខ្ញុំធ្លាប់ចូលចិត្តសាច់គោ។

ក៖ ចាស!

ខ៖ សាច់គោដូចជាឆាជាមួយនឹងប៉េងប៉ោះ។

ក៖ អញ្ចឹងចូលចិត្តមួយហ្នឹងជាងគេហោ?

ខ៖ បាទ!

ក៖ អញ្ចឹងបងចេះធ្វើម្ហូបសម្រាប់ពិសារអីទេ?

ខ៖ ខ្ញុំហ្នំ...ចេះធ្វើតើ។

ក៖ ចាសហើយចេះធ្វើម្ហូបពីអ្នកណាគេដែរបង?

ខ៖ និយាយរួមខ្ញុំមើលឪពុកម្ដាយរបស់ខ្ញុំ ហើយខ្ញុំសួរគាត់ខ្លះៗទៅខ្ញុំចេះ។

ក៖ មិនមែនរៀនមកពីប្រពន្ធទេហោ?

ខ៖ ពីប្រពន្ធក៏រៀនដែរ។

ក៖ ចាសអញ្ចឹងបងសម្រាប់ពេលបងទំនេរហា បងចូលចិត្តធ្វើអីគេជាងគេហា?

ខ៖ ពេលទំនេរខ្ញុំចូលចិត្តធ្វើអីផ្សេងៗដូចជារើសគ្រឿងអីផ្សេងៗដែលខូចៗហ្នឹង ខ្ញុំជុសជុល។

ក៖ ជុសជុលឡើងវិញអញ្ចឹងទៅ?

ខ៖ ហ្នឹងហើយ ចូលចិត្តខាងហ្នឹង។

ក៖ ចាសអញ្ចឹងបងសម្រាប់ទំនេរពីការងារក៏ដូចជារបររកស៊ីជាមួយនឹងភរិយារបស់បងអញ្ចឹង ហា តើពេលកន្លែងណាដែលបងចូលចិត្តទៅកម្សាន្តខ្លាំងជាងគេ?

ខ៖ ភាគច្រើនខ្ញុំតាមមាត់សមុទ្រ។

ក៖ ចាស!

ខ៖ ហើយបើមិនអញ្ចឹងតាមមាត់ទន្លេ សួនច្បារ។

ក៖ សប្បាយ។

ខ៖ បាទ!

កៈ អញ្ចឹងបងតើបងចូលចិត្តស្តាប់បទចម្រៀងទេ?

ខៈ បាទចូលចិត្តស្តាប់តើ។

កៈ ចូលចិត្តស្តាប់ដែរ អញ្ចឹងតើអ្នកចម្រៀងមួយណាដែលបងស្រលាញ់ពេញចិត្តជាងគេហា?

ខៈ ខ្ញុំស្រលាញ់ជាងគេគឺលោកព្រាប សុវត្ថិ។

កៈ ហ្អ៎...គាត់ច្រៀងពិរោះ?

ខៈ បាទ!

កៈ អញ្ចឹងបង បងចេះច្រៀងទេ?

ខៈ ខ្ញុំហ្អ៎...?

កៈ ចាស!

ខៈ ចេះខ្លះដែរ។

កៈ ចេះខ្លះដែរ?

ខៈ បាទ!

កៈ អញ្ចឹងលេងឧបករណ៍តន្ត្រីអញ្ចឹងហា បងចេះទេ?

ខៈ ខ្ញុំអត់ចេះទេ ខ្ញុំស្រលាញ់ខាងហ្នឹង។

កៈ ស្រលាញ់ខាងហ្នឹង ចុះមិនព្រមទៅរៀនស្រលាញ់ខាងហ្នឹងហើយ?

ខៈ របៀបថាបើខ្ញុំទៅរៀន ខ្ញុំអត់មានលុយចិញ្ចឹម។

កៈ ចាស!

ខៈ សម្រាប់ជីវភាពរបស់យើង យើងមានប្រពន្ធមានអី បើនៅកម្លោះទៅយើងទៅរៀនហើយ។

កៈ ហ្នឹងហើយ អញ្ចឹងបងសម្រាប់ក្នុងប្រទេសយើង យើងតែងតែដឹងពីជំនាន់ប៉ុល ពតឬក៏សង្គ្រាម អីផ្សេងៗហើយមែនទេបង?

ខៈ បាទ!

កៈ អញ្ចឹងបង តើក្រុមគ្រួសារបង ប៉ាម៉ាក់បងហ្នុំ...មានដែលប្រាប់បងអំពីជំនាន់សង្គ្រាមហ្នឹងទេ?

ខៈ គាត់ប្រាប់ដែរ។

កៈ ម៉េចដែរបង?

ខៈ គាត់ថាពីជំនាន់ប៉ុល ពតគាត់ពិបាក។

កៈ ចាស!

ខៈ គាត់ហូបអត់គ្រប់គ្រាន់ ហើយជួនកាលគាត់បបរមួយកូនចានតូចអញ្ចឹងទៅហូបអត់គ្រប់។
កៈ ចាស!

ខៈ ជួនកាលគាត់ថាគាត់ទៅដាំដំឡូងខ្ទុឡនឯង ដាំហ្នឹងហា ទៅហូបបើគេចាប់បានក៏គេមិនទុក ដែរ។

កៈ ចាសហ្នឹងហើយ អញ្ចឹងបងដូចជាបងប្អូនបង ខាងម្ដាយបងឬក៏ឪពុកបងអញ្ចឹងហា ដូចជាគាត់សល់ពីជីវិតហ្នឹងហា មានច្រើននាក់ទេ?

ខៈ គាត់មានច្រើនដែរ។

កៈ ចាសរួចផុតពីរបបសង្គ្រាមហ្នឹងហោ?

ខៈ បាទៗ!

កៈ ចាសហ្នឹងហើយ អញ្ចឹងបងដូចជាដឹងទេថាម្ដាយរបស់បងដល់ពេលគាត់បែកពីជំនាន់ប៉ុល ពតមក តើគាត់រកស៊ីអីគេដែរ?

ខៈ គាត់អឺ...បែកពីជំនាន់ប៉ុល ពតមកគាត់លក់អាកោរ លក់ពោតអីអញ្ចឹងទៅ។

កៈ ចាស!

ខៈ លក់នៅភ្នំពេញ។

កៈ ហ្នឹងហើយ ចាំទេថាពួកគាត់រៀបការនៅឆ្នាំណាបង?

ខៈ ខ្ញុំអត់ចាំផង។

កៈ អត់ចាំទេ?

ខៈ បាទ!

កៈ អញ្ចឹងបងនៅក្នុងជីវិតរបស់បងអញ្ចឹងហា តើអ្វីដែលបងចាំជាងគេនៅក្នុងជីវិតរបស់បង ដែលមិនអាចបំភ្លេចបានអញ្ចឹងហា?ពេលវេលាណាបងអាចរៀបរាប់ពីជីវិតរបស់បងពេលទាំងអស់ហ្នឹងហា?

ខៈ អត់ចាំ។

កៈ អ្វីចាំជាងគេព្រឹត្តិការណ៍អីដែលបងដក់ជាប់ក្នុងចិត្តមិនអាចបំភ្លេចបានអញ្ចឹងហា?

ខៈ បាទខ្ញុំចាំបានត្រង់តែខ្ញុំ ឪពុកម្ដាយខ្ញុំពេលដែលខ្ញុំធំដឹងក្ដីមកឃើញឪពុក...។

កៈ ចាស!

ខៈ រាងកម្សត់ដែរ។

កៈ ចាស!

ខៈ ហ្នឹងហើយហើយជួនកាលគាត់ទៅ គាត់ទៅកំពង់សោមបាត់ទៅ ខ្ញុំនៅជាមួយអ៊ុំជាមួយជាមួយអ៊ុំអញ្ចឹង តាអីអញ្ចឹងទៅណា ទាន់តាយាយស្លាប់បាត់ហើយ មានអារម្មណ៍ថាពិបាកហាហ្នឹងហើយអត់មានអ្នកទីពឹងនៅក្បែរខ្លួន ហើយបែរឪពុកគាត់នៅឆ្ងាយ គាត់អត់ទាន់ដឹងដំណឹងគាត់អត់មក កាលហ្នឹងគាត់ទៅធ្វើទាហាន ហ្នឹងហើយគាត់ធ្វើទាហានដល់អញ្ចឹងទៅឮមកថាឮគេផ្សាយតាមប៉ុស្តិ៍វិទ្យុ ម៉ែខ្ញុំប្រាប់ខ្ញុំតាមហ្នឹងដែរណាស់។

កៈ ចាស!

ខ៖ ផ្សាយថា ជន់ វុទ្ធី ហ្នឹងគាត់បានស្លាប់បាត់ហើយអត់បានមកវិញទេ អញ្ចឹងម៉ែខ្ញុំក៏ប្រហែលជា៥ ៦ឆ្នាំទៅគាត់ចាំទៅ គាត់ចេះតែដើរគាត់ខូចចិត្តគាត់ គាត់ទៅរកស៊ីឆ្ងាយៗគាត់ទៅកំពង់សោមអីអញ្ចឹងទៅ គាត់ទៅតាមគេជាមួយស្រីៗគ្នាគាត់ហ្នឹងហា។

ក៖ ចាស!

ខ៖ ទៅពេលរកលុយបានគាត់ទៅៗ ពេលគាត់សល់លុយ សល់កាក់ទៅគាត់មកលេងតាយាយហ្នឹង មកលេងយាយ លេងតាយាយស្លាប់បាត់ហើយ។

ក៖ ចាស!

ខ៖ គាត់ទិញអីមកជូបគាត់ សប្បាយចិត្តណាស់ពេលជួបគាត់។

ក៖ ហ្នឹងហើយ!

ខ៖ ពេលឮថាប៉ាគាត់ស្លាប់ហើយណា។

ក៖ ចាស!

ខ៖ ធ្វើម៉េចបើខ្ញុំនៅតូចមិនសូវដឹងអីដែរ ពេលប្រហែលជា៤ ៥ឆ្នាំទៀតទៅខ្ញុំដឹងថាប៉ាខ្ញុំគាត់មកលេងមកអី។

ក៖ ហាកអញ្ចឹងគាត់អត់ទាន់ស្លាប់ទេ?

ខ៖ គាត់អត់ទាន់ស្លាប់ផង។

ក៖ ហ៊ី...ហើយអញ្ចឹងម៉េចទៅ?

ខ៖ ប៉ាបង្កើតពេលមកគាត់ស្រងាកចិត្ត ម៉ែខ្ញុំគាត់ស្រងាកទៅ ម៉ែខ្ញុំគាត់មានអារម្មណ៍មួយថាដែរគ្រាន់ថាគាត់អត់ទាន់ស្លាប់ផងហ្នឹង អញ្ចឹងគាត់...។

ក៖ អញ្ចឹងហេតុអីក៏ថាគាត់ស្លាប់វិញ?

ខ៖ បាទដល់ពេលអញ្ចឹងប៉ាខ្ញុំគាត់មកហើយគាត់យកប្រពន្ធនៅហ្នឹងហើយៗហ្នឹង។

ក៖ ហ៊ឺ...! បានគាត់មកអញ្ចឹងទៀត។

ខ៖ ដល់ពេលហើយគាត់ គាត់ក៏និយាយលេងជាមួយម៉ែខ្ញុំទៅ ប៉ាខ្ញុំឮសូរតាថាមិនបាច់ យក វិញទេបើគេនៅរស់គេអត់មកវិញ ហើយគេទៅយកប្រពន្ធហើយ យើងមិនបាច់ទៅយក។

ក៖ ហើយពេលហ្នឹងម៉ែបងមានប្ដីនៅ?

ខ៖ ម៉ែខ្ញុំនៅហ្នឹង។

ក៖ នៅហ៊ឺ...?

ខ៖ នៅទេ គាត់យកប្រពន្ធមុនម៉ែខ្ញុំតើ ហើយអញ្ចឹងម៉ែខ្ញុំគាត់អន់ចិត្ត។

ក៖ ចាស!

ខ៖ គាត់ចេះតែដើររកស៊ីទៀតទៅ មានបានជួបប៉ាចុងខ្ញុំក្រោយ។

ក៖ ចាសចេះតែដាច់ចិត្តចោលប្រពន្ធកូនដែរ។

ខ៖ ហ្នឹងហើយ!

ក៖ ហ៊ឺ...ចាស អញ្ចឹងបងនៅក្រោយពេលបងរៀបការជាមួយបងវេតហា តើមានកូនប៉ុន្មាននាក់ ដែរឥឡូវ?

ខ៖ ឥឡូវខ្ញុំមានកូន១ ២នៅក្នុងពោះមួយទៀត ទម្ងន់។

ក៖ ចាសអញ្ចឹងមួយមាននៅនេះហើយ អញ្ចឹងមួយទៀតមាននៅក្នុងពោះ?

ខ៖ បាទទម្ងន់៥ខែទៀតហើយ។

ក៖ ស្រីឬក៏ប្រុសបង?

ខ៖ ប្រុស។

ក៖ ប្រុស?

ខ៖បាទ!

ក៖ អូយឆ្លាស់គ្នាល្អណាស់អញ្ចឹង ស្រីមួយប្រុសមួយបងវេតឡូយណាស់អញ្ចឹង។ ហ្នឹងហើយ អញ្ចឹងបងតើកូនស្រីរបស់បងគាត់ឈ្មោះអីគេវិញ?

ខ៖ កូនស្រីខ្ញុំឈ្មោះលីហ្សា។

ក៖ លីហ្សា អីគេលីហ្សាវិញបង?

ខ៖: ឈ្មោះ ឈ្មោះនៅក្នុងបញ្ជីជាតិឈ្មោះវត្តី អឺ...វណ្ណៈ វត្តី។

ក៖ ចាសអញ្ចឹងបងអត់មានកូនចិញ្ចឹមកូនអីណាបងអី?

ខ៖ អត់ផង។

ក៖ អត់មានទេ  ហើយកូននៅក្នុងពោះហ្នឹងមានត្រៀមឈ្មោះដាក់ឱ្យហើយនៅ?

ខ៖ នៅទេ។

ក៖ នៅទេហោ?

ខ៖ អត់ទាន់ហ៊ាន។

ក៖ អញ្ចឹងបង តើឥឡូវចូលដល់នេះវិញម្តង ភរិយាបងវិញម្តង តើអឺ...ភរិយារបស់បងឈ្មោះអីគេ?

ខ៖ គាត់ឈ្មោះបងវេត។

ក៖ អីគេ ត្រកូលអីគេវិញបង?

ខ៖ ផេន សាវេត។

ក៖ ចាសតើប្រពន្ធបងមានចរិកលក្ខណៈម៉េចដែរបង?

ខ៖ គាត់...មុនខ្ញុំស្រលាញ់គាត់មុនដំបូង គាត់ចរិកគាត់ទន់ភ្លន់ សុភាពរាបសា គាត់អត់ចេះ អាហិចអាហាចដូចគេហា អញ្ចឹងបានខ្ញុំស្រលាញ់គាត់ គាត់នឹងធឹង គាត់ឃើញមនុស្សប្រុស គាត់អត់ចេះដៀងភ្នែកមើលទេ គាត់របៀបដូចថាគាត់ គាត់គឺនៅតែខ្លួនគាត់។

កៈ ហ្នឹងហើយ!

ខៈ គាត់អត់ចេះលេងសើចទេ។

កៈ អ្នកណាគេម៉េចៗទៅបងវេតអត់ខ្វល់?

ខៈ បាទ!

កៈ ចាសអញ្ចឹងបង តើឥឡូវដូចជាគ្រួសារបងនិងបងប្រកបរបររកស៊ី រកស៊ីអីគេដែរបង?

ខៈ ឥឡូវខ្ញុំបើកធ្វើជាងម៉ាស៊ីនម៉ាស្ទូត ម៉ាស៊ីនសាំងហើយនឹងរើម៉ូតូ។

កៈ ចាសហើយដាច់ទេបង?

ខៈ វាមួយៗដែរ។

កៈ ចាសហ្នឹងហើយ ឥឡូវមានម៉ូយច្រើនហោ?

ខៈ បាទមានគួរសមដែរ។

កៈ ចាសហ្នឹងហើយ អញ្ចឹងបងៗមានឱ្យមីអូនទៅរៀនទេ?

ខៈ ខ្ញុំថាក្នុងឆ្នាំហ្នឹងខ្ញុំឱ្យទៅហើយ។

កៈ  ចាសអញ្ចឹងមូលហេតុអីបានបងឱ្យមីអូនទៅរៀនបង?

ខៈ ចង់ឱ្យចេះដឹងនឹងគេជ្រៅជ្រះ។

កៈ ចាសហ្នឹងហើយ ចាសបងគិតថាការសិក្សាម៉េចដែរ?

ខៈ ការសិក្សាវាមានចំណេះចេះដឹងវាអាចជួយដល់ប្រទេសខ្មែរយើង បាទចេះដឹងច្រើន។

កៈ ចាសឱ្យប្រទេសជាតិរីកចម្រើនបងហ្នំ...?

ខៈ បាទធ្វើឱ្យប្រទេសជាតិរីកចម្រើន។

កៈ អញ្ចឹងបង តើបងត្រូវធ្វើដូចម្តេចដើម្បីឱ្យក្រុមគ្រួសារបងមានសុភមង្គលហាបង?

ខ៖ យើងត្រូវឱ្យជាជីវភាពរបស់យើងឱ្យគ្រប់គ្រាន់ ហើយយើងឱ្យកូនទៅរៀនគ្រប់គ្រាន់។

ក៖ ចាសហ្នឹងហើយ។

ខ៖ បាទហើយការសម្លៀកបំពាក់យើងមានគ្រប់បែបយ៉ាង។

ក៖ ចាស!

ខ៖ ហើយនឹងអាជីប ជំនាញចំណូលចូលរបស់យើងវាមិនបានច្រើន តែវាចូលបានតិចៗរហូត គ្រប់គ្នាអញ្ចឹងទៅណា។

ក៖ ចាសហ្នឹងហើយ។

ខ៖ មានសុភមង្គល។

ក៖ ចាសហ្នឹងហើយ សុខសប្បាយ។

ខ៖ ថែមទាំកុំឱ្យឈ្លោះគ្នា។

ក៖ ហ្នឹងហើយ! ចា អញ្ចឹងបងគ្រួសារមិនមែនអង្គុយមានតែសុខសប្បាយរហូតទេមែនទេបង?

ខ៖ បាទមានឈឺខ្លះ។

ក៖ ចាសអញ្ចឹងដល់ពេលមានបញ្ហាបងដោះស្រាយម៉េចដែរ?

ខ៖ ពេលអញ្ចឹងយើងត្រូវដើម្បីរកលុយទុក ដើម្បីពេលដែលថ្ងៃណាមួយដូចជាកូនដូចជាយើង ដូចជាខ្ញុំអីឈឺទៅយើងអាចមានលុយហ្នឹងយកទៅមើលជម្ងឺ។

ក៖ ចាសអញ្ចឹងបង តើគ្រួសារមានអត្ថន័យយ៉ាងណាចំពោះជីវិតរបស់បងហា?

ខ៖ គ្រួសារហ្ន៎...?

ក៖ ចាស!

ខ៖ អត្ថន័យ?

ក៖ បងស្រលាញ់គ្រួសាររបស់បងទេ?

ខ៖ បាទស្រលាញ់។

ក៖ ហើយគិតថារស់នៅខ្វះពួកគាត់បានទេ?

ខ៖ អត់បានទេ។

ក៖ អត់បានទេ?

ខ៖ បាទ!

ក៖ ទោះមីអូនខូចម៉េចក៏ដោយហេ?

ខ៖ បាទ!

ក៖ ចាសហ្នឹងហើយ អញ្ចឹងបងតើបងមានបទពិសោធន៍អ្វីខ្លះដែលល្អនៅក្នុងជីវិតដែលចង់ចែកចាយទៅកាន់កូនចៅបងជំនាន់ក្រោយ?

ខ៖ បាទខ្ញុំមានបទពិសោធន៍មួយថា យើងត្រូវតែមានចំណេះឱ្យចេះឱ្យច្រើន។

ក៖ ចាស!

ខ៖ មិនថាចំណេះអីក៏ដោយយើងត្រូវតែចាប់យកទាំងអស់ តាំងជាអក្សរខ្មែរ អក្សរអង់គ្លេស ហើយដូចជាការបច្ចេកទេស។

ក៖ ចាស!

ខ៖ គ្រឿងអីផ្សេងៗយើងត្រូវតែចេះឱ្យច្រើន។

ក៖ ល្អមែនទែន។

ខ៖ បាទវាអត់ខុស។

ក៖ ចាសបងមួយនេះគឺជាសំណួរមួយចុងក្រោយអញ្ចឹងហា បងដោយសារការសម្ភាសនេះដូចជាបងនឹងស្តាប់ការសម្ភាសនេះ កូនចៅបងជំនាន់ក្រោយនឹងស្តាប់ឮទាំងអស់គ្នាដោយសារពួកគាត់នឹងបើកស្តាប់អីអញ្ចឹងណាស់បង តើបងមានដំបូន្មានអ្វីខ្លះចង់ផ្តែផ្តាំទៅកូនចៅបង?

ខ៖ ខ្ញុំចង់ឱ្យគាត់រៀនសូត្រឱ្យបានជ្រៅជ្រះ ហើយកុំឱ្យគាត់ដើរលើផ្លូវងងឹតដូចជាគ្រឿងញៀន សូមកុំឱ្យគាត់ចង់សាក ចង់ជក់កុំយល់។

ក៖ ចាស!

ខ៖ ព្រោះអាហ្នឹងគ្មានប្រយោជន៍ទេ។

ក៖ ហ្នឹងហើយ!

ខ៖ បាទ!

ក៖ វាធ្វើឱ្យជីវិតវិនាសមែនទេបង?

ខ៖ បាទហ្នឹងហើយ វាធ្វើឱ្យយើងភ្លេចម៉ែឪហើយធ្វើឱ្យយើងក្លាយទៅជាមនុស្សបាត់ផ្សារនៅក្នុងសង្គម។

ក៖ ហ្នឹងហើយ!

ខ៖ យើងត្រូវជៀសវាឱ្យឆ្ងាយ គឺយើងកុំចង់ស្គាល់វា។

ក៖ ហ្នឹងហើយបង។

ខ៖ យើងត្រូវតែនិយាយថាទេគឺគ្រឿងញៀន។

ក៖ ហ្នឹងល្អមែនទែន ឱ្យគាត់គេចផុតពីអីគេទៀតបងក្រៅពីគ្រឿងញៀនអញ្ចឹងហា?

ខ៖ បាទឱ្យគាត់គេចដូចជាស្រាកុំហូបឱ្យសោះ។

ក៖ ចាសហ្នឹងហើយ។

ខ៖ បាទ!

ក៖ តែដាក់ទៅឈឺហើយពិបាកទៀត។

ខ៖ បាទ!

ក៖ វង្វេងវង្វាន់អស់អាលីង អញ្ចឹងបងខ្ញុំសូមថ្លែងអំណរគុណដល់បងខ្លាំងមែនទែនដែលឱ្យខ្ញុំសម្ភាសនៅក្នុងថ្ងៃនេះ ហើយការសម្ភាសនេះខ្ញុំនឹងដាក់ចូលទៅក្នុងវេបសាយដែលខ្ញុំនិយាយខាងលើនឹងហាបង និយាយទៅកូនចៅបងជំនាន់ក្រោយនឹងបានឮនូវអ្វីទាំងអស់ហ្នឹង ហើយអរគុណច្រើនបង៕